**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ: ៩៧១ សហវ.ប្រក.

# ប្រកាស
## ស្ដីពី
## ការបង្កើត លេខាធិការដ្ឋាននៃគណៈកម្មាធិការឥណទានសំរាប់អភិវឌ្ឍន៍ជនបទ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលខ នស/៩៤/០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រឹត្យលខ នស/រកត/១២៩៨/៨៨ ចុះថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងឥស្សរជនជាអនុរដ្ឋលេខាធិការនៃក្រសួងនិងរដ្ឋលេខាធិការដ្ឋាននៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ អនុក្រឹត្យលខ ០៤/អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលខ ៧៨/អនក្រ/បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្ដីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលខ ៦៧ អនក្រ បក ចុះថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០០៥ ស្ដីពីកែសំរួល សមាសភាព

និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការឥណទានសំរាប់អភិវឌ្ឍន៏ជនបទ

- បានឃើញ ប្រកាសលេខ ៥៨៤/សហវ/ប្រក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការកែសំរួល ការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញតំរូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**ប្រការ១:** បង្កើតលេខាធិការដ្ឋាននៃគណៈកម្មាធិការឥណទានសំរាប់អភិវឌ្ឍន៏ជនបទ(**គឥអជ**) ដែលស្ថិតនៅក្រោមនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយលេខាធិការដ្ឋាននេះមានការិយាល័យគ្រប់គ្រងមីក្រូហិរញ្ញវត្ថុ និង ហិរញ្ញប្បទានសំរាប់សហគ្រាសធុនតូច និង មធ្យមជាសេនាធិការ ។

**ប្រការ២:** លេខាធិការដ្ឋាននៃ **គឥអជ** មានតួនាទី និង ភារកិច្ចដូចខាងក្រោមៈ

- ជាសេនាធិការអោយ **គឥអជ**
- សំរបសំរួលការងាររដ្ឋបាលទូទៅរបស់លេខាធិការដ្ឋានជាមួយស្ថាប័នពាក់ពន្ធ័ផ្សេងៗក្នុងក្របខណ្ឌ័ **គឥអជ**
- រៀបចំកិច្ចប្រជុំ សំណុំលិខិត ឯកសាររដ្ឋបាលផ្សេងៗតាមរយៈការណែនាំរបស់ **គឥអជ**
- រៀបចំធ្វើរបាយការណ៏ជូនសមាជិកនៃ **គឥអជ** និង ស្ថាប័នពាក់ពន្ធ័ផ្សេងៗទៀត អំពីសកម្មភាពមីក្រូហិរញ្ញវត្ថុទាំងអស់
- ចូលរួមរៀបចំក្របខណ្ឌ័យុទ្ធសាស្ត្រ និង គោលនយោបាយជាតិក្នុងវិស័យមីក្រូហិរញ្ញវត្ថុ សំរាប់ការអភិវឌ្ឍន៏ជនបទ ដើម្បីដាក់ជូន **គឥអជ** ពិនិត្យ និង អនុម័ត
- សំរបសំរួល និង តាមដានការអនុវត្តយុទ្ធសាស្ត្រ និង គោលនយោបាយជាតិក្នុងវិស័យមីក្រូ-ហិរញ្ញវត្ថុ តាមរយៈចក្ខុវិស័យនិងផែនការអភិវឌ្ឍន៏វិស័យហិរញ្ញវត្ថុសំរាប់ឆ្នាំ ២០០១-២០១០ របស់រាជរដ្ឋាភិបាល
- រៀបចំកម្មវិធី និង ផែនការសកម្មភាព ដើម្បីអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុ រួមមានការគៀងគរជំនួយពីបរទេស ទ្វេភាគី និង ពហុភាគី សំរាប់តំរូវការឥណទានជនបទ ព្រមទាំងជំរុញឱ្យស្ថាប័នហិរញ្ញវត្ថុក្នុងស្រុកចូលរួមចំណែកគាំទ្រដល់ការអភិវឌ្ឍន៏វិស័យឥណទានជនបទនៅកម្ពុជា ដើម្បីដាក់ជូន **គឥអជ** ពិនិត្យ និង សំរេច
- តាមដានការប្រើប្រាស់ និង ការអនុវត្តន៏គំរោងឥណទានសំរាប់អភិវឌ្ឍន៏វិស័យមីក្រូហិរញ្ញវត្ថុ ដែលទទួលបានហិរញ្ញប្បទានពីរាជរដ្ឋាភិបាល ពីស្ថាប័នហិរញ្ញវត្ថុជាតិ និង អន្តរជាតិ ពីប្រទេសជាមិត្ត និង ពីប្រភពឥណទានផ្សេងទៀត ដើម្បីធានាឱ្យការប្រើប្រាស់ឥណទានទាំងនេះ ស្របតាម

យុទ្ធសាស្ត្រ និង គោលនយោបាយជាតិដែលបានកំណត់

- ចូលរួមតាមដានប្រតិបត្តិការនៃការផ្តល់ឥណទានធនធានរបស់ស្ថាប័ន ឬ ប្រតិបត្តិករមីក្រូ-ហិរញ្ញវត្ថុ ដែលមានអាជ្ញាបណ្ណ ឬ ចុះបញ្ជីនៅធនាគារជាតិនៃកម្ពុជា ដើម្បីធានាឱ្យបាននូវប្រសិទ្ធិភាព និង និរន្តភាពនៃហិរញ្ញប្បទានលើវិស័យនេះ
- ចូលរួមរៀបចំក្នុងការកសាងសមត្ថភាពស្ថាប័នគ្រប់គ្រង និង សមត្ថភាពប្រតិបត្តិករមីក្រូ-ហិរញ្ញវត្ថុ តាមរយៈការរៀបចំសិក្ខាសាលាជាតិ-អន្តរជាតិ និងការស្វែងរកជំនួយផ្សេងៗ ដើម្បីពង្រឹងសមត្ថភាពលើវិស័យនេះ
- ចូលរួមផ្តល់យោបល់ និង នាំមកនូវគំនិតថ្មីៗដើម្បីចូលចំណែកក្នុងការអភិវឌ្ឍន៍វិស័យមីក្រូ-ហិរញ្ញវត្ថុ ជូន **គជទាន**
- បំពេញភារកិច្ចផ្សេងទៀតដែលប្រធាន **គជទាន** ណែនាំ ។

**ប្រការ៣:** ប្រកាស ឬ លិខិតបទដ្ឋានទាំងឡាយ ដែលផ្ទុយពីសេចក្តីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤:** អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានបុគ្គលិក និង គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៥

**គាត ឈន់**

**ចំលងជូន:**

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ធនាគារជាតិនៃកម្ពុជា
-ធនាគារអភិវឌ្ឍន៍ជនបទ
-គណៈកម្មាធិការ (គជទាន)
"ដើម្បីជូនជ្រាបជាព័ត៌មាន និង សហការ"
-ដូចប្រការ ៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ